ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក ស វ

# Work Activities

ប្រចាំខែមីនា ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជីវសុវត្ថិភាព | ១ |
| ២- | កិច្ចប្រជុំពិភាក្សាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការបង្កើតសហគមន៍ប្រើប្រាស់ទឹក | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១២ | ៣ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជីវសុវត្ថិភាព

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជីវសុវត្ថិភាព** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងបរិស្ថាន។



ក្រសួងបរិស្ថានបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជីវសុវត្ថិភាព ក្នុងគោលបំណងលើកកម្ពស់ការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាពនិងអនុក្រឹត្យស្តីពីយន្តការនិងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព ធានាទប់ស្កាត់ និងការពារផលប៉ះពាល់អវិជ្ជមានមកលើការអភិវឌ្ឍមកលើមនុស្ស ដោយផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់សាធារណជនអំពីសក្តានុពលនៃហានិភ័យដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ស្រាវជ្រាវនិងអភិវឌ្ឍន៍ជីវបច្ចេកវិទ្យាទំនើប។ លើសពីនេះទៀត សេចក្តីព្រាងអនុក្រឹត្យនេះមានគោលបំណងរៀបចំ និងអភិវឌ្ឍធនធានមនុស្ស ផ្តល់ព័ត៌មានដល់សាធារណជនឲ្យយល់ច្បាស់ពីសក្តានុពលនៃហានិភ័យ ដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់មកលើជីវចម្រុះ សុខភាពមនុស្ស សត្វ បរិស្ថាន និងស្រាវជ្រាវអភិវឌ្ឍជីវបច្ចេកវិទ្យាទំនើប សម្រាប់វិទ្យាសាស្ត្រនិងបរិស្ថាន(១)។

អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើសេចក្តីព្រាងនេះ ហើយបានកត់សម្គាល់ថា សេចក្តីព្រាងអនុក្រឹត្យនេះមានមូលដ្ឋានច្បាប់ច្បាស់លាស់ ក៏ប៉ុន្តែខុសទម្រង់ និងមានការខ្វះខាតមួយចំនួនដូចជា ច្បាប់និងបទដ្ឋានគតិយុត្តក្នុងមូលបទមិនគ្រប់គ្រាន់ និងចែងពីការបង្កើតថ្នាក់ការិយាល័យដែលជាសមត្ថកិច្ចរបស់ប្រកាសរដ្ឋមន្ត្រី។ សេចក្តីព្រាងអនុក្រឹត្យនេះ គួរចែងខ្លីជាងនេះ ដោយនិយាយតែពីការបង្កើតលេខាធិការដ្ឋានដែលមានឋានៈស្មើនាយកដ្ឋានចំណែកឯថ្នាក់ការិយាល័យចំណុះ ត្រូវទុកបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រី។

អង្គប្រជុំបានស្នើឲ្យក្រសួងយកសេចក្តីព្រាងឯកសារនេះទៅកែសម្រួលឡើងវិញតាមអនុសាសន៍របស់អង្គប្រជុំ ហើយនឹងដាក់ប្រជុំជំនាញបច្ចេកទេសពេលក្រោយទៀត។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជីវសុវត្ថិភាព។

## កិច្ចប្រជុំពិភាក្សាឡើងវិញលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# នីតិវិធីនៃការបង្កើតសហគមន៍ប្រើប្រាស់ទឹក

កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុំ កុសល** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) និង លោកជំទាវ **លី ខួចឡេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើតសហគមន៍ប្រើប្រាស់ទឹក** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកអគ្គលេខាធិការរង និងមន្ត្រី នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្ដីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងធនធានទឹក និងឧតុនិយម។

សូមរំឭកថាសេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើតសហគមន៍ប្រើប្រាស់ទឹក បានឆ្លងអង្គប្រជុំទី១ កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៩ ក្រោមអធិបតីភាពឯកឧត្តម **ទី យ៉ាវ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ។



អង្គប្រជុំពេលនោះបានកត់សម្គាល់ថា សេចក្ដីព្រាងអនុក្រឹត្យនេះមានភាពមិនច្បាស់លាស់ ធ្វើឲ្យមានការយល់ច្រលំថា បើមានសហគមន៍កសិករប្រើប្រាស់ទឹកចំនួន១០០ នោះត្រូវមានអនុក្រឹត្យចំនួន១០០ ដែរ។ ប៉ុន្តែតាមពិតមិនដូចច្នេះទេ គឺទំនងជាចង់បង្កើតក្បួន ដើម្បីឲ្យសហគមន៍ទាំងនេះស្របតាមការបង្គាញដោយច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក។ បើគិតពីទិដ្ឋភាពច្បាប់ គ្មានអ្វីខុសទេ ប៉ុន្តែជាទម្រង់ពិបាកយល់ និងមិនច្បាស់លាស់។ ដូច្នេះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារចង្អៀត មានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងសាមី ដើម្បីរៀបចំកែសម្រួលទៅតាមគំរូសម្រាប់សហគមន៍មូលដ្ឋាន។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាឡើងវិញលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើតសហគមនប្រើប្រាស់ទឹកកែសម្រួលថ្មីនេះ ក្រោយពីបានពិភាក្សាផ្លាស់ប្ដូរយោបល់គ្នា អង្គប្រជុំកត់សម្គាល់ថា សេចក្ដីព្រាងអនុក្រឹត្យកែសម្រួលថ្មីនេះ មិនឆ្លុះបញ្ចាំងតាមស្មារតីអង្គប្រជុំចង្អៀតទេ។

អង្គប្រជុំបានស្នើឲ្យក្រសួងយកសេចក្ដីព្រាងឯកសារនេះទៅកែសម្រួលឡើងវិញ ហើយនឹងដាក់ប្រជុំជំនាញបច្ចេកទេសពេលក្រោយទៀត។ អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាជាបណ្ដោះអាសន្ន។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១២*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ឈាលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកុម្ភៈនេះសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ០,៤% ធៀបនឹងខែមុន និងកើនឡើង ៥,៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ កំណើនសន្ទស្សន៍ថ្លៃខែ **កុម្ភៈ/មករា** ជាចំបងមានការរួមចំណែកនៃក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត ៣៣% ការដឹកជញ្ជូន៧៧% និងភោជនីយដ្ឋាន ២៨%។ គួរកត់សម្គាល់ថា បម្រែបម្រួលថ្លៃទំនិញក្នុងខែនេះ គឺក្រុមម្ហូបអាហារមានការចុះថ្លៃធៀបនឹងខែមុន ដែលក្នុងនោះមានការចុះថ្លៃនៃក្រុមសាច់ និងបន្លែ។

| ការឡើងថ្លៃគួរឲ្យកត់សម្គាល់បើធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| *ក្រុមទំនិញ* | | *មុខទំនិញ* | |
| ម្ហូបអាហារ:+៦,៩% | ការដឹកជញ្ជូន:+៨,៣% | សាច់ជ្រូក:+១៨% | សាច់គោស្រស់:+១៧% |
| ភោជនីយដ្ឋាន:+៦,៨% | | បន្លែ:+៩,៥% | ប្រេងសាំង:+១៤% |
| ទំនិញនិងសេវាកម្មផ្សេងៗ:+៩,៦%។ | | ប្រេងម៉ាស៊ូត:+១៧% ។ | |

* ការវិភាគជាលាយលក្ខណ៍អក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។

* ព័ត៌មាន និងតួលេខពណ៌បៃតងសំដៅលទ្ធផលល្អប្រសើរ និងពណ៌ក្រហមសំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងបរទេស សញ្ញាក្បៀសនៅក្នុងអត្ថបទសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ជា Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០–២០១២

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា^P | មេសា^P | ឧសភា^P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៦% | ៥,៥% | ៥,៤% | | | | | | | | |
| | ខែមុន | ១,០ | ០,៤ | ១,១% | ០,៩% | ០,៧% | | | | | | | | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |

P: តួលេខខែមិនា មេសា និងឧសភា ឆ្នាំ២០១២ ជាតួលេខព្យាករ**ដោយ**ក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

### ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




ក្រាហ្វ១ បង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១១ និង ២០១២។ក្រាហ្វនេះក៏បង្ហាញផងដែរ នូវតួលេខការព្យាករបីខែទៅមុខនៃអត្រាអតិផរណា (ធៀបនឹងខែដូចគ្នាឆ្នាំមុន)។

➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | អត្រាខែកុម្ភៈ ២០១២ | អត្រាខែមករា ២០១២ | អត្រាខែកុម្ភៈ ២០១១ | *ប្រភេទ* | អត្រាខែកុម្ភៈ ២០១២ | អត្រាខែមករា ២០១២ | អត្រាខែកុម្ភៈ ២០១១ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០១៥៛/១$ | ៤០៦៤៛/១$ | ៤០៣៦៛/១$ | **បាត/ដុល្លារ** | ៣០,៣៣បាត/១$ | ៣១,១៣បាត/១$ | ៣០,៦២បាត/១$ |
| **៛/បាត** | ១៣២៛/១បាត | ១៣០៛/១បាត | ១៣២៛/១បាត | **ដុង/ដុល្លារ** | ២០៨២០ ដុង/១$ | ២០៩០០ ដុង/១$ | ២០៨៨៥ ដុង/១$ |
| **៛/ដុង** | ០,១៩២៛/១ដុង | ០,១៩៣៛/១ដុង | ០,១៩៣៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ក្នុង**ខែកុម្ភៈ ឆ្នាំ២០១២ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳ ***ចំណូលថវិកាជាតិអនុវត្តបាន ៦១៨,៣ពាន់លានរៀល*** *(មធ្យមប្រចាំខែ ៦៥% នៃគម្រោង) ក្នុងនោះ:* **ចំណូលចរន្ត ៦១៥,១ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩៦% នៃគម្រោង)និង***ចំណូលមូលធន ៣,១ ពាន់លានរៀល*** ។

↳បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ** កើនឡើង ១២% និងកើនឡើង ១៩% *បើធៀបនឹងខែដូចគ្នាឆ្នាំមុន*។ កំណើន ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុននេះ ជារួមបណ្តាលមកពីការកើនឡើងនៃចំណូលចរន្ត ៤៥% ។

### ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ និង ២០១២ (ពាន់លានរៀល)




↳នៅក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធ មានចំនួន ៥១៣,៣ ពាន់លានរៀល បើធៀបនឹងខែមុន កើនឡើង ២៩% និងកើនឡើង ៤៧% បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

- ពន្ធនិងអាករគយកើនឡើង ១០% បើធៀបនឹងខែមុន និងកើនឡើង៣២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន
- ចំណូលពន្ធដារស្ថិតនៅថេរបើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធថយចុះ ៣៥% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៧% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

| **ក្នុងចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ**<br>(ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ➢ ពន្ធ-អាករគយ:+១០% | ( +៣២%) | ➢ នេសាទ: -៥% | (+១១០%) |
| ➢ ចំណូលពន្ធដារ: 0% | (+២៥%) | ➢ អាកាសចរណ៍ស៊ីវិល: +៦០២% | (+៤%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +១% | (-៣៧%) | ➢ ផលទុនទេសចរណ៍: +១៧០៤% | (+២៥%) |
| ✧ កាស៊ីណូ : -២៨% | (+៦៣%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: +៥៨% | (+១១៧%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក :+៣៣% | (-៥៣%) | ➢អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -១០% | (-៤%) |
| ✧ ការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+២៩% | (-៥៣%) | | |

➩ ***ចំណាយថវិកាជាតិ***អនុវត្តបាន ៨៥ ពាន់លានរៀល (*មធ្យមប្រចាំខែ ១០% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៨៥ ពាន់លានរៀល (*មធ្យមប្រចាំខែ ១៦% នៃគម្រោង*) និងពុំមានតួលេខ**ចំណាយមូលធន**ទេ ក្នុងខែមករា និងខែកុម្ភៈ។

➩ *បើធៀបនឹងខែមុន***ចំណាយថវិកាជាតិ**ថយចុះ ៥% និងថយចុះ ៨០% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការថយចុះនៃចំណាយថវិកាជាតិធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងខែនេះជាចំបងបណ្តាលមកពីចំណាយចរន្តថយចុះ ៧៧%។

➩ *តុល្យភាពថវិកាជាតិនៃខែកុម្ភៈមាន**អតិរេក ៥៣៣** ពាន់លានរៀល*។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈ ឆ្នាំ ២០១២ មានលក្ខណៈដូចខាងក្រោម៖

➩ រូបិយវត្ថុ $M_2$ មានចំនួន **២៤ ៧៧៣** ពាន់លានរៀល កើនឡើង២,៦% ធៀបនឹងខែមុន និងកើនឡើង ២៥% ក្នុងរយៈពេល ១២ខែ។

➩កំណើនរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន ជារួមបណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង ២,៤% និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង ៣,៨%។

➩យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**ក្នុងសេដ្ឋកិច្ច**មានចំនួន ១៨,៣% នៃរូបិយវត្ថុ$M_2$និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨១,៧%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែកុម្ភៈ២០១២**




**សមាមាត្រចំនួនប្រាក់រៀល និងរូបិយវត្ថុ$M_2$**

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | ១៩,២% | ១៨,៣% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | | | | | | | | | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែកុម្ភៈ ២០១២៖ ក្នុងវង់ក្រចកជាបម្រែបម្រួលរយៈពេល១២ខែ**




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **៣ ១៣២ លានដុល្លារ** កើនឡើង ៣,១% បើធៀបនឹងខែមុន និងកើនឡើង ១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ជារួមមានការកើនឡើង។ ក្នុងខែនេះមានចំនួន **៨ ០២០ ពាន់លានរៀល** កើនឡើង ៥% បើធៀបនឹងខែមុន និងកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្ដល់ឥណទានដោយធនាគារពាណិជ្ជ*** *ក៏កើនឡើងជាប្រចាំដែរ*។ ក្នុងខែនេះ មានចំនួន **១៨ ៤២២ ពាន់លានរៀល** កើនឡើង ១,២% បើធៀបនឹងខែមុន និងកើនឡើង ៣៥% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្ដល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ក្នុងខែនេះ មានចំនួន **២ ៨០៤ ពាន់លានរៀល** កើនឡើង ៤,៤% បើធៀបនឹងខែមុន និងកើនឡើង ៤៩% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***អត្រាការប្រាក់ប្រចាំឆ្នាំ នាខែកុម្ភៈ ២០១២៖***

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៣៤% | 0 | –៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,៩៣% | 0 | **–២៥%** |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៥% | 0 | **+២%** |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៣,៥៤% | +១% | **–១៥%** |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែកុម្ភៈ ឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

**កសិកម្ម៖**

- ✓ផលិតកម្មនេសាទមានចំនួន **៩០ ពាន់តោន** ថយចុះ ២៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ឧស្សាហកម្ម៖**

- ✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា មានចំនួន **២៣៧GWh** ថយចុះ៣% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង២២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន **១,៣GWh** ថយចុះ៨៧% ធៀបនឹងខែមុន និងថយចុះ ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៩៣លានដុល្លារ ថយចុះ២៥% បើធៀបនឹងខែមុនប៉ុន្តែ កើនឡើង ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន —កុម្ភៈ២០១២* | *ចំនួន—មករា២០១២* | *ចំនួន—កុម្ភៈ២០១១* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៧ | ២ | ១០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៩ | ១១ | ២៦ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០ | ១០ | ១២ |

**សំណង់៖**

| *ប្រភេទ* | *ពាន់ម² —កុម្ភៈ ២០១២* | *ពាន់ម² —មករា២០១២* | *ពាន់ម² —កុម្ភៈ ២០១១* |
|---|---|---|---|
| ▪ លំនៅឋាន | ២៤២ | ៧១ | ១៣៧ |
| ▪ ឧស្សាហកម្ម | ២៧០ | ៥៧ | ៤៤ |
| ▪ ទេសចរណ៍ | ១៩៤ | ១៣ | ៦៥ |
| … | | | |
| អនុញ្ញាតសរុប | ៧៤២ | ១៨៤ | ២៧៣ |

✓ **សំណង់អនុញ្ញាតឲ្យសាងសង់**មានចំនួន **៧៤២ ពាន់ម²** កើនឡើង ៣០២% បើធៀបនឹងខែមុន និងកើនឡើង ១៧២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់មានចំនួន **២២៦ លានដុល្លារ** កើនឡើង ៣០៨% បើធៀបនឹងខែមុន និងកើនឡើង១៦៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ **សំណង់ដែលពេញនិយម** គឺសំណង់ឧស្សាហកម្ម (៣៦% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) លំនៅឋាន (៣៣% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និង ទេសចរណ៍ (២៦% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

**ការងារ៖**

| *ប្រភេទ* | *ចំនួន (នាក់)—កុម្ភៈ២០១២* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១ ៩៩០ | -៨% | -១% |
| *អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន* | ៦ ៥៤៦ | +១៣២% | +១៤២% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៥ ១៨១ | +៣៦១% | +២៦០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៣៦៥ | -១៨% | +៧% |

**វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែកុម្ភៈ មានចំនួន ១៥ ដែលជាទុនវិនិយោគស្មើនឹង **១៤១លានដុល្លារ**។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន **៣២ពាន់នាក់**។

| *ប្រភេទ* | *កុម្ភៈ២០១២* | *មករា២០១២* | *កុម្ភៈ២០១១* |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ១៤១ | ២១៥ | ១០៥ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៨ | ១៩ | ៥ |
| វិស័យឧស្សាហកម្ម | ១១៣ | ១៩៧ | ២៣ |
| វិស័យទេសចរណ៍ | ០ | ០ | ៧៧ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| **ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន)** | ១៥ | ១៦ | ៧ |
| **ចំនួនពលករ (ពាន់នាក់)** | ៣២ | ៣៣ | ៦ |

**សេវាកម្ម និងទេសចរណ៍៖**

✓**ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| *ប្រភេទ* | *ចំនួន—កុម្ភៈ២០១២* | *ចំនួន—មករា២០១២* | *ចំនួន—កុម្ភៈ២០១១* |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៧៤ | ២៩៦ | ២៣០ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ១ | ៥ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៧៨ | ២៣៥ | ២៤៦ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ) មានចំនួន៤៣៥ ពាន់តោនថយចុះ៦% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៦%ក្នុងរយៈពេល ១២ខែ ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលបើធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: +៥% | (+៥៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: -៣% | (+៧៥%) |
| ▪ កំពង់ផែកំពង់សោម: -១៩% | (+៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៤៦% | (+១៥១%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៤ | +៥៨% | +៣% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ |
| ▪ ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៥៩ | +២៤% | +៤០% |
| ▪ ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ៣២២ | -៨% | +២៦% |
| ✓ តាមផ្លូវអាកាស | ១៦៨ | -៩% | +១៦% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៤ | -៧% | +៣៩% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាខែកុម្ភៈមានចំនួន ១៩ ៤៧ ពាន់លានរៀល បើធៀបនឹងខែមុនថយចុះ ១១% ប៉ុន្តែកើនឡើង ១៦% បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| *ទំនិញ* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ប្រេងម៉ាស៊ូត | +១៣% | +៣២% | ជីនិងថ្នាំកសិកម្ម | +៥០% | +៨% |
| ឧស្ម័ន | +៤២% | +១៥១% | ប្រេងសាំង | –៩% | –២០% |
| ដែកសំណង់ | +២៤% | +៥៦% | ប្រេងខ្មៅ | –៨% | –១៤% |
| ស៊ីម៉ង់ត៍ | +២៣% | +៥០% | គ្រឿងអេឡិចត្រូនិក (គ្រឿង) | –១៥% | +៦២% |
| រថយន្តសរុប (ព.ល.រ) | +១០% | +៦៩% | ម៉ូតូ (គ្រឿង) | –៦៦% | –៤៨% |
| រថយន្តសរុប (គ្រឿង) | +៩% | +៥៤% | ផ្លែឈើនិងបន្លែ | –៤៤% | +២៣% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤៣% | –៥៦% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | –២២% | +១២% |

➡ **ការនាំចេញ** ក្នុងខែកុម្ភៈ ឆ្នាំ២០១២ មានចំនួន ១ ៦៥២ ពាន់លានរៀល (៨៥% នៃការនាំចូល) ថយចុះ ៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៨% បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| *ទំនិញ* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១ ១២០% | +៧៥៦% | ផលិតផលនេសាទ | –៨៣% | –៣៩% |
| អង្ករ | +៥៧% | +១១១% | វាយនភណ្ឌនិងស្បែកជើង | –១១% | +១៩% |
| កៅស៊ូ | +៤០% | +៤៤% | | | |

➡ ក្នុងខែកុម្ភៈនេះ ជញ្ជីងពាណិជ្ជកម្មមាន *ឱនភាពចំនួន ២៩៥ ពាន់លានរៀល ស្មើនឹង ៧៤ លានដុល្លារ ស.រ.អ.* ។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈ ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | +៣៣% | -៥៣% | — |
| ២ | កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | +២៩% | -៥៣% | — |
| ៣ | *ការផ្គត់ផ្គង់ដោយវារីអគ្គិសនី* | -៨៧% | -១២% | — |
| ៤ | ***ការបើកថ្មី*** ឧស្សាហកម្មធុនតូច និងសិប្បកម្ម | +៧៣% | -២៧% | — |
| ៥ | ***ការបន្ត*** ឧស្សាហកម្មធុនតូច និងសប្បកម្ម | 0 | -១៧% | — |
| ៦ | ក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារ តាមរបបពិត | -២៤% | -២៨% | — |
| ៧ | *ទំនិញឆ្លងកាត់ផែកំពង់សោម* | -១៩% | +៧% | — |
| ៨ | *ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុង* | +៤៦% | +១៥១% | — |
| ៩ | ***ការនាំចូលរថយន្ត (គិតជាលុយ)*** | +១០% | +៦៩% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) **អតិផរណា:** ក្នុងខែកុម្ភៈ ឆ្នាំ ២០១២ តួលេខបង្ហាញការថយចុះនៃថ្លៃក្រុមម្ហូបអាហារធៀបនឹងខែមុន ប៉ុន្តែក្រុមការដឹកជញ្ជូនបានរួមចំណែកយ៉ាងធំ ទៅលើកំណើនសន្ទស្សន៍ថ្លៃ **កុម្ភៈ/មករា**។

តម្លៃខ្ពស់នៃប្រេងសាំង និងម៉ាស៊ូត ជាមូលហេតុដែលធ្វើឲ្យមុខទំនិញផ្សេងៗមានការឡើងថ្លៃខ្ពស់។

ការឡើងថ្លៃថាមពលគឺជាកត្តាចម្បងដែលការរាំងដល់ការរីកលូតលាស់សេដ្ឋកិច្ចកម្ពុជា។

២) តួលេខវិស័យសំណង់បង្ហាញសន្ទុះគួឲ្យចាប់អារម្មណ៍នាដើមឆ្នាំ២០១២នេះ។ ជាពិសេសសំណង់លំនៅឋាន (សង់ដោយក្រុមហ៊ុន) សំណង់ឧស្សាហកម្ម និងទេសចរណ៍។ នេះដោយសារកត្តាដូចខាងក្រោម៖

ក) សំណង់ធំៗដូចជាខុនដូ (មកដល់បច្ចុប្បន្នមានចំនួន ២៧៩អគារ)

ខ) សំណង់បូរី (បច្ចុប្បន្ននៅទីក្រុងភ្នំពេញមានចំនួន ២៧កន្លែង)

គ) ការពង្រីកទីក្រុងភ្នំពេញ

ឃ) សំណង់រោងចក្រកាត់ដេរ

ង) សំណង់ម៉ាស៊ីនកិនស្រូវ

***សេចក្តីសន្និដ្ឋានដូចខាងក្រោម៖***

*១) តួលេខវិនិយោគបង្ហាញថា ក្នុងពីរខែដើមឆ្នាំនេះទុនវិនិយោគ ដែលជាចម្បងលើវិស័យកសិកម្ម និងឧស្សាហកម្ម មានចំនួន ៣៥៦ លានដុល្លារ កើនឡើង ៤០% បើធៀបនឹងរយៈពេល ២ខែដូចគ្នាឆ្នាំ២០១១។ រីឯ វិស័យសំណង់ បើប្រៀបធៀបរយៈពេល ២ខែដើមឆ្នាំដូចគ្នា ២០១២/២០១១ ក៏មានការកើនឡើង ៤០% ដែរ។ នេះអនុញ្ញាតឲ្យយើងសន្និដ្ឋានថា ជាសញ្ញាល្អសម្រាប់ការលូតលាស់សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១២។*

*២) ថ្លៃខ្ពស់នៃថាមពល (ឥន្ធនៈ និងអគ្គិសនី) ជាកត្តាលំបាកសម្រាប់កម្ពុជាក្នុងការអភិវឌ្ឍន៍។*

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៣/១២<br>ម៉ោង ០៨:៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៣/១២<br>ម៉ោង ០៩ : ០០ នាទី | ជួបប្រជុំពិភាក្សាការងារ (ការសាងសង់អគារសារមន្ទីរសព្វទស្សន៍) ជាមួយអគ្គរដ្ឋទូតប្រទេសឥណ្ឌា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៥/០៣/១២<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តព្រៃមេលង និងពិធីសម្ពោធអគារសិក្សា**វិទ្យាល័យ សុខ អាន ព្រៃមេលង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តព្រៃមេលង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ។ |
| ៤ | ០៥/០៣/១២<br>ម៉ោង ១៥:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតសុខាភិបាលលើកទី៣៣ និងការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំលើកទី១០ លើសមិទ្ធិផលសុខាភិបាលឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៥ | ០៦/០៣/១២<br>ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី១៦ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១៣ ជូនដល់គរុនិស្សិត និងគរុសិស្សនៃ**វិទ្យាស្ថានជាតិអប់រំ** ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៦ | ០៨/០៣/១២<br>ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី១០១ ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "អ្នកម្តាយដ៏ឆ្នើមរបស់ខ្ញុំ" ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ០៩/០៣/១២<br>ម៉ោង ១៥:១៥ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅ នៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១២/០៣/១២<br>ម៉ោង ០៩:០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការត្រួតពិនិត្យវាយតម្លៃ និងចរចារជាមួយកងវិស្វកម្មសម្តេចតេជោ **ហ៊ុន សែន** ខេត្តសៀមរាប លើការងារស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ពីភ្លើងស្តុបសណ្ឋាគារសុខាអង្គរ ដល់អាកាសយានដ្ឋានខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | **១២/០៣/១២ ម៉ោង ១៦:០០ នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើះ<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅ នៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>២-សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **១៣/០៣/១២ ម៉ោង ០៨:៣០ នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ នៃលទ្ធផលចុងក្រោយជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១ ក្រោមអធិបតីភាព ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | **១៣/០៣/១២ ម៉ោង ១៥:០០ នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១៤/០៣/១២ ម៉ោង ០៨:៣០ នាទី** | ចូលរួមជាកិត្តិយសក្នុងសម័យប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកិត្តិយស និងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **១៦/០៣/១២ ម៉ោង ០៨:៣០ នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការងារអនុវត្តគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) ជាមួយភាគីកូរ៉េ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **១៩/០៣/១២ ម៉ោង ០៨:០០ នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ និងពិធីសម្ពោធអគារសិក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| ១៥ | **២០/០៣/១២ ម៉ោង ១៨:៣០ នាទី** | ចូលរួមក្នុងវេទិកាអន្តរជាតិ ប្រទេសនិយាយភាសាបារាំង នៅសណ្ឋាគារ Himawari ។ |
| ១៦ | **២២/០៣/១២ ម៉ោង ០៩:០០ នាទី** | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៧ | **២២/០៣/១២ ម៉ោង ១៤:៣០ នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១០-២០១១ និងលើកទិសដៅឆ្នាំសិក្សា២០១១-២០១២ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតអប់រំ។ |
| ១៨ | **២២/០៣/១២ ម៉ោង ១៧:០០ នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជាមួយឯកអគ្គរាជទូតសហគមន៍អឺរ៉ុប នៅ European Union Residence។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៩ | ២៦/០៣/១២ ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់គម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ដំណាក់កាលទី៣ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡាដ្ឋានជាតិអូឡាំពិក (ច្រកចូលទល់មុខក្លោងទ្វារ វត្តសំពៅមាស ខាងលិច សង្កាត់វាលវង់ ខណ្ឌ៧ មករា)។ |
| ២០ | ២៦/០៣/១២ ម៉ោង ១៥:០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃលើការងារសាងសង់លូប្រអប់ចំនួន ០៨កន្លែង នៅផ្លូវវាងខាងត្បូងក្រុងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | ២៧/០៣/១២ ម៉ោង ១០:០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ Mr. NOTEBAERT អគ្គនាយក ក្រុមហ៊ុនសម្បទាន VINCI នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | ២៧/០៣/១២ ម៉ោង ១៥:៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជីវសុវត្ថិភាព។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយក រដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៨/០៣/១២ ម៉ោង ០៩:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំ វេទិកាប្រជាជនអាស៊ាន ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |
| ២៤ | ២៩/០៣/១២ ម៉ោង ០៨:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយ និងអនុវត្តស្មារតីកិច្ចព្រមព្រៀងទទួល ស្គាល់គ្នាទៅវិញទៅមក ក្នុងមុខជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន" និងពិធីប្រគល់សញ្ញាបត្របណ្ឌិត គ្រប់គ្រងទេសចរណ៍ (ជំនាញអេកូទេសចរណ៍) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | ២៩/០៣/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មា ធិការជាតិជីវសុវត្ថិភាព។<br>៣-បញ្ហាផ្សេងៗ ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៦ | ២៩/០៣/១២ ម៉ោង ១៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងអបអរសាទរជូន ឯកឧត្តមបណ្ឌិត **ថោង ខុន** ដែលបានទទួល សញ្ញាបត្របណ្ឌិតគ្រប់គ្រងទេសចរណ៍ (ផ្នែកអេកូទេសចរណ៍) ពីសាកលវិទ្យាល័យសេដ្ឋកិច្ចជាតិ ហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារណាហ្គាវើល។ |
| ២៧ | ៣១/០៣/១២ ម៉ោង ១៩:០០ នាទី | ចូលរួមពិធីជប់លៀងក្នុងឱកាសបើកកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-អឺរ៉ុប លើកទី២ ជាមួយឯកអគ្គរាជទូតសហគមន៍អឺរ៉ុប នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តព្រៃមេលង និងពិធីសម្ពោធអគារសិក្សា**វិទ្យាល័យ សុខ អាន ព្រៃមេលង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តព្រៃមេលង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ។ |
| ២ | ០៦/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី១៦ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១៣ ជូនដល់គរុនិស្សិត និងគរុសិស្សនៃ**វិទ្យាស្ថានជាតិអប់រំ** ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៣ | ១៤/០៣/១២ | ចូលរួមជាកិត្តិយសក្នុងសម័យប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៨/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំ វេទិកាប្រជាជនអាស៊ាន ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |

## ឯកឧត្តម ឧុយ ចៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តព្រៃមេលង និងពិធីសម្ពោធអគារសិក្សា**វិទ្យាល័យ សុខ អាន ព្រៃមេលង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តព្រៃមេលង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ។ |
| ២ | ១២/០៣/១២ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅ នៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>២-សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៤/០៣/១២ | ចូលរួមជាកិត្តិយសក្នុងសម័យប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៨/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំ វេទិកាប្រជាជនអាស៊ាន ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១២

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តព្រៃមេលង និងពិធីសម្ពោធអគារសិក្សា**វិទ្យាល័យ សុខ អាន ព្រៃមេលង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅវត្តព្រៃមេលង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ។ |
| ២ | ០៦/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី១៦ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១៣ ជូនដល់គរុនិស្សិត និងគរុសិស្សនៃ**វិទ្យាស្ថានជាតិអប់រំ** ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៣ | ១២/០៣/១២ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅ នៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>២-សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៤/០៣/១២ | ចូលរួមជាកិត្តិយសក្នុងសម័យប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកិត្តិយស និងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៩/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ និងពិធីសម្ពោធអគារសិក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| ៦ | ២៨/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំ វេទិកាប្រជាជនអាស៊ាន ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលសន្និសីទចតុមុខ។ |
| ៧ | ២៩/០៣/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបើកសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយ និងអនុវត្តស្មារតីកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក ក្នុងមុខជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន" និងពិធីប្រគល់សញ្ញាបត្របណ្ឌិតគ្រប់គ្រងទេសចរណ៍ (ជំនាញអេកូទេសចរណ៍) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមការងារសាងសង់អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ពិធីបំពាក់គ្រឿងឥស្សរិយយសជូនអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនវិស្វកម្មយូណាន និងសមាជិកលេខាធិការដ្ឋានក្រុមការងារសាងសង់អគារមិត្តភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី




កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានពិធីបំពាក់គ្រឿងឥស្សរិយយសជូនអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនវិស្វកម្មយូណាន និងសមាជិកលេខាធិការដ្ឋានក្រុមការងារសាងសង់អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងជាប្រធានក្រុមការងារសាងសង់អគារមិត្តភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី

ដោយមានការចូលរួមពីសំណាក់ ឯកឧត្តម **ម៉ិន អ៊ុយ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការគ្រប់គ្រងការប្រើប្រាស់ និងថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី លោក **លី សាវឆៀន** តំណាងក្រុមហ៊ុនវិស្វកម្មយូណាន និងសហការីក្រុមហ៊ុនវិស្វកម្មយូណាន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាអនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក និងមន្ត្រី នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី។



ក្នុងឱកាសនោះ ឯកឧត្តម **យឹម ណុលឡា** បានមានប្រសាសន៍ថា ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយឥតឧបមា ដោយបាន ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចាត់ខ្ញុំជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ចូលរួមជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរយយស ជូនអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនវិស្វកម្មយូណាននៃប្រទេសចិន និងសមាជិក ចំនួន ០៣រូប នៃលេខាធិការដ្ឋានក្រុមការងារសាងសង់អគារមិត្តភាពនាពេលនេះ។

ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលចិន និងប្រជាជនចិន ដែលតែងតែផ្តល់ជំនួយជួយដល់ប្រទេសកម្ពុជាយើងលើគ្រប់វិស័យ មានដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ស្ពាន) កសិកម្ម (ផ្នែកធារាសាស្ត្រ ទំនប់ទឹកនៅបាត់ដំបង) ឧស្សាហកម្ម (ទំនប់វារីអគ្គិសនីនៅកោះកុង និងពោធិសាត់) ដែលជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍន៍នឹងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាយើង។ ដោយឡែកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋាភិបាលចិនបានផ្តល់ជូនអគារមិត្តភាពនេះ ព្រមទាំងបន្តជួយបណ្តុះបណ្តាលដល់អ្នកបច្ចេកទេសកម្ពុជាលើការប្រើប្រាស់ និងថែទាំអគារតាំងពីសាងសង់ត្រូវបានបញ្ចប់នៅខែមីនា ឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន។ ហើយដើម្បីឲ្យទីស្តីការគណៈរដ្ឋមន្ត្រីមានការិយាល័យគ្រប់គ្រាន់សម្រាប់បម្រើការងារ រដ្ឋាភិបាលចិននឹងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យាជូនទីស្តីការគណៈរដ្ឋមន្ត្រី នាឆ្នាំខាងមុខដ៏ខ្លីនេះផងដែរ។ បន្ថែមពីនេះទៀត រដ្ឋាភិបាលកម្ពុជាក៏បានស្នើសុំរដ្ឋាភិបាលចិននូវអគារអង្គរក្សចំណុះ ១០០នាក់ ដើម្បីរក្សាធានានូវសន្តិសុខសុវត្ថិភាពជូន អគារសន្តិភាព និងអគារមិត្តភាព។ ទំនាក់ទំនងដ៏ល្អរវាងប្រទេសកម្ពុជា និងប្រទេសចិន មានតាំងពីសម័យអង្គរមកម្លេះ។ សាវតារបានបញ្ជាក់ថា មានជនជាតិចិនម្នាក់ឈ្មោះលោក **ជីវ តាក្វាន់** បានរស់នៅមួយរយៈធំនៅក្នុងបរមរាជវាំងនៃក្រុងអង្គរ ហើយបានសរសេរឯកសារដ៏សំខាន់



មួយចំនួន ជាពិសេសស្តីអំពីការរស់នៅរបស់ប្រជាជនខ្មែរយើងក្នុងសម័យអង្គរដ៏រុងរឿង។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី**

អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រីនេះមាន ៧ជាន់ (គិតទាំងជាន់ផ្ទាល់ដី) និងក្រោមដីមួយជាន់ លើផ្ទៃដីសាងសង់សរុបចំនួន ៣៩,៧០៥ម² និងមានផ្ទៃអគារសរុបចំនួន ៣២,៥៨០ម² ហើយអគារមិត្តភាពនេះមានបណ្តោយ ១១៥.៥ម ទទឹង ៤៨ម និងកំពស់ ៣៩.៩ម។

បន្ទាប់ពីសាងសង់រួច រដ្ឋាភិបាលចិនបានផ្តល់នូវកម្មវិធីសហប្រតិបត្តិការបច្ចេកទេស ដើម្បីធានានូវការប្រើប្រាស់អគារមិត្តភាពនេះឲ្យមានប្រសិទ្ធភាពខ្ពស់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ហើយក្រុមហ៊ុនសំណង់វិស្វកម្មយូណាន ជាអ្នកទទួលអនុវត្តកម្មវិធីសហប្រតិបត្តិការបច្ចេកទេស ដោយសហការជាមួយគណៈកម្មការគ្រប់គ្រងការប្រើប្រាស់ និងថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការសម្របសម្រួលពីក្រុមការងារសាងសង់។

ជាមួយគ្នានេះដែរ ខ្ញុំសូមកោតសរសើរចំពោះគណៈកម្មការគ្រប់គ្រងការប្រើប្រាស់ និងថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមការងារសាងសង់ និងក្រុមហ៊ុនសំណង់វិស្វកម្មយូណាន ដែលបានសហការយ៉ាងល្អប្រសើរលើការងារកន្លងមក ហើយបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីធានាឲ្យបានប្រសើរនូវការប្រើប្រាស់លើអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាអគារតំណាងនូវចំណងមិត្តភាពជាអមតៈរវាងប្រទេសទាំងពីរ កម្ពុជា-ចិន។

សូមឲ្យមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានរីកចំរើនជាអមតៈ។

នៅទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីសួរស្តី ដ៏បវរមហាប្រសើរជូនដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ក្នុងឱកាសចូលឆ្នាំថ្មីខាងមុខនេះ សូមឲ្យបានប្រកបដោយសេចក្តីសុខ សេចក្តីចំរើនគ្រប់ប្រការ សុខភាពល្អបរិបូរ អាយុយឺនយូរ សុភមង្គលក្នុងគ្រួសារ កុំបីឃ្លាងឃ្លាតឡើយ។

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | **ឯកឧត្តម គីម សយសាម៉ាឡែន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | **ឯកឧត្តម ខ៉ាន់ តិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអត្ថបទ: | **ឯកឧត្តម អេង រត្នមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | **លោក ម៉ក់ ឆារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | **លោក សយ វាស្នា** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | **លោក មុត ភក្កដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in